**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**

**និងប្រព័ន្ធយុត្តិធម៌**

**អង្គភាពគ្រប់គ្រងគម្រោង**

**លេខ:00៩/0៧ របក.កកចនយ**

## របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ មេសា ឆ្នាំ ២00៧របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ មេសា ឆ្នាំ ២០០៧ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមាន អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមាន អង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួន ស្របតាមបេសកកម្មដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

**១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

ក. <u>ការងាររដ្ឋបាល</u>

-រៀបចំលិខិតអញ្ជើញចូលរួមប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែ-ទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃ អង្គារ ទី ២៤ ខែ មេសា ឆ្នាំ ២០០៧

- ផ្ញើលិខិតទៅលោក Wolfgang Meyer អ្នកតំណាងអង្គការ Konrad-Adenauer Stiftung ស្តីពីសៀវភៅក្បួនសម្រាប់បង្កើតច្បាប់ (Handbook for Law Making) នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៧

- ផ្ញើលិខិតទៅឯកឧត្តម ប៉ែន ដារេត ស្តីពីគម្រោង ដើម្បីសុំជំនួយពីអាល្លឺម៉ង់ នៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៧

-ធ្វើដីកាអមទៅក្រសួងស្ថាប័នពាក់ព័ន្ធ បញ្ជូនរបាយការណ៍ស្តីពីលទ្ធផលនៃការ អនុវត្តកម្មវិធីសកម្ម ភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ឆ្នាំ ២០០៦ តារាង ស្តីពីស្ថានភាពនៃការអនុវត្តកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រ កំណែទម្រង់ច្បាប់ និង តុលាការ ប្រចាំឆ្នាំ ២០០៦ និង បញ្ជីគម្រោងសម្រាប់ការអនុវត្ត យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ជាសង្ខេបដើម្បីទុកជាមូលដ្ឋាន សម្រាប់ការប្រជុំ អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៧

-ធ្វើលិខិតស្នើសុំត្រៀមរបាយការណ៍ស្តីពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុម ប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ស្តីពីតុលាការពាណិជ្ជកម្មសម្រាប់ការ ប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ (ជូនចំពោះឯកឧត្តម ម៉ៅ ថូរ៉ា អនុរដ្ឋលេខាធិការ ក្រសួង ពាណិជ្ជកម្ម )

ខ. <u>ការងារកំណែទម្រង់</u>

- ប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធ-យុត្តិធម៌ នៅថ្ងៃ ទី ២៤ ខែ មេសា ឆ្នាំ ២០០៧ ពិនិត្យលទ្ធផល នៃការអនុវត្តកម្មវិធីសកម្មភាពសម្រាប់ការ អនុវត្តកំណែទម្រង់ច្បាប់ និងតុលាការ និងទិសដៅសម្រាប់ការអនុវត្តជាបន្ត
- ប្រជុំអនុក្រុមការងារបច្ចេកទេសចម្រុះ ទិសដៅយុទ្ធសាស្ត្រលេខ ១ និង ៦
- ប្រជុំអង្គភាពគ្រប់គ្រងគម្រោង ពិនិត្យ កែសម្រួលស្តង់ដារតុលាការគំរូ (Standard Model Court) នៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៧
- ជួបពិភាក្សាជាមួយអ្នកតំណាងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ដោះស្រាយ បញ្ហាពាក់ព័ន្ធដល់ការរៀបចំប្រព័ន្ធទិន្នន័យគម្រោងលេខ ១.១.១ (សិទ្ធិទទួលបានយុត្តិធម៌នៅ កម្ពុជា ) នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៧
- ចូលរួមប្រជុំ ពិនិត្យគម្រោង CCJAP III នៅក្រុងព្រះសីហនុ នៅថ្ងៃទី ២៥-២៦-២៧ ខែ មេសា ឆ្នាំ ២០០៧
- ប្រជុំអនុក្រុម (Sub-Group) យុទ្ធសាស្ត្រទី ៤ និង ៥។

គ. <u>ផ្សេងៗ</u>

- ទទួលជួបក្រុមការងាររបស់ CSD (Centre Social Development) សុំមតិយោបល់លើរបាយការណ៍ផ្សេងៗ ដែលអង្គការបានផ្សព្វផ្សាយ នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៧
- ទទួលប្រជុំពិនិត្យរបាយការណ៍វាយតំលៃលើកម្មវិធី CCJAP II នៅក្រសួងយុត្តិធម៌ នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៧
- ចូលរួមប្រជុំពិនិត្យរបាយការណ៍ស្ដីពីភាពជឿនលឿនក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិ ២០០៦-២០១០ នៅក្រសួងផែនការ
- ចូលរួមប្រជុំនៅសាលាភូមិន្ទរដ្ឋបាល (L'Ecole Royale d'Administration) ពិនិត្យកិច្ចសហ ប្រតិបត្តិការអន្តរជាតិ រវាងសាលាភូមិន្ទរដ្ឋបាល និងសាកលវិទ្យាល័យស៊ីដនី។

**២-សន្និដ្ឋាន**

ក្នុងខែ មេសា ឆ្នាំ ២០០៦ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជា អង្គភាពប្រតិបត្តិ បានខិតខំបំពេញការងារ យ៉ាងសកម្មក្នុងការរៀបចំ មូលដ្ឋានសម្រាប់ដំណើរការការងាររបស់ Sub-Group/TWG ដើម្បីរុញច្រានការអនុវត្តកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ អោយបានខ្លាំងក្លា និងបានរៀបចំប្រជុំអង្គភាព សម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ។

**៣-ទិសដៅអនុវត្តក្នុងខែបន្ត**

- គ្រោងរៀបចំប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្ដីព្រាងស្ដង់ដា (Standard) សម្រាប់តុលាការគំរូ នៅថ្ងៃព្រហស្បតិ៍ ទី ១៧ ខែ ឧសភា ឆ្នាំ ២០០៧
- គ្រោងរៀបចំប្រជុំ ដើម្បីពិនិត្យពិភាក្សាលើគម្រោងស្ដីពីការរៀបចំប្រព័ន្ធសូចនាករតាមដាន ការអនុវត្តសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការទាំងមូល
- បន្តធ្វើបច្ចុប្បន្នភាពកម្មវិធីសកម្មភាព និងបញ្ជីគម្រោង តាមរយៈអនុក្រុម (Sub-Group/TWG)
- រៀបចំកម្មវិធីបណ្ដុះបណ្ដាលមន្ត្រីអង្គភាពគ្រប់គ្រងគម្រោង និងកម្មវិធីបណ្ដុះបណ្ដាលមន្ត្រីគោល តាមក្រសួង ស្ថាប័នអនុវត្ត

- បន្តការពិភាក្សាជាមួយក្រសួងហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធ អំពីវិស័យយុត្តិធម៌ទាំងមូល ។

*រាជធានី ភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧*

**អ្នកធ្វើរបាយការណ៍**

**បានឃើញ និងឯកភាព**

**នាយកអង្គភាពគ្រប់គ្រងគម្រោង**

**ស៊ុយ ម៉ុងលាង**

**ហ៊្វីង សុកុល**